A joint Australian Government &
State/Territory Health initiative

Khmer



# តើអ្នកបានធ្វើតែសផាប់ស្មៀ ចុងក្រោយបំផុតនៅពេលណា?

ជម្ងឺមហារីកកស្បូនភាគច្រើនអាចនឹងបង្ការបាន ប្រសិនបើស្ត្រីម្នាក់ៗបានធ្វើតែសផាប់ស្មៀ (Pap Smear) នៅរៀងរាល់ពីរឆ្នាំម្តង

**National Cervical Screening Program**

DON'T MAKE EXCUSES, MAKE AN APPOINTMENT

## តើអ្វីទៅជាផាប់ស្មៀ?

ផាប់ស្មៀគឺជាតែសងាយស្រួលមួយ ដើម្បីពិនិត្យមើលសុខភាពកស្បូន(មាត់ច្រកស្បូន)។ គេត្រូវការពេលតែប៉ុន្មាននាទីប៉ុណ្ណោះ ហើយមិនធ្វើឲ្យឈឺចាប់អ្វីទេ។

តែសនេះគឺជាមធ្យោបាយដ៏ល្អបំផុត ដើម្បីរកឲ្យឃើញព្រមទាំងការពារជម្ងឺមហារីកកស្បូន។

## ហេតុអ្វីបានជាគេធ្វើតែសផាប់ស្មៀ?

តែសផាប់ស្មៀអាចបង្ហាញឲ្យឃើញនូវសញ្ញាឲ្យដឹងជាមុនពីមហារីកកស្បូន។ កស្បូនរបស់អ្នកនៅខាងក្នុងយោនីដែលជាមាត់ច្រកនៃស្បូនរបស់អ្នក។




ជួនកាលកោសិកាតូចៗនៃកស្បូនចាប់ផ្តើមប្តូរពីភាពធម្មតា ទៅភាពមិនប្រក្រតី។ ភាពនេះអាចកើតឡើងដោយអ្នកមិនដឹងខ្លួនផង។

កោសិកាដែលខុសប្លែកពីធម្មតាទាំងនេះអាចព្យាបាលបានដោយវេជ្ជបណ្ឌិត មុននឹងវាក្លាយទៅជាមហារីក។

មហារីកកស្បូនដែលកើតជាទូទៅនោះអាចជៀសវាងបាន រហូតដល់ទៅ៩០ភាគរយ ប្រសិនបើការផ្លាស់ប្តូរកោសិកាពីដំបូង ត្រូវបានគេរកឃើញ ហើយព្យាបាលបានទាន់ពេល។

## តើអ្នកណាត្រូវការធ្វើតែសផាប់ស្មៀនេះ?

ប្រសិនបើអ្នកធ្លាប់បានសេពកាម អ្នកត្រូវធ្វើតែសផាប់ស្មៀនេះរៀងរាល់ពីរឆ្នាំម្តង។

ស្ត្រីគួរតែធ្វើតែសផាប់ស្មៀឲ្យបានទៀងទាត់ រហូតដល់អាយុ ៧០ឆ្នាំ។

## តើគេធ្វើតែសផាប់ស្មៀដោយរបៀបណា?






## គេធ្វើដូចតទៅនេះ...

ជាដំបូង វេជ្ជបណ្ឌិតប្រាប់អ្នកឲ្យដោះសំលៀកបំពាក់ចេញចាប់ពីចង្កេះចុះក្រោម ហើយឲ្យដេកផ្ងារ ដើម្បីឲ្យគេពិនិត្យមើល។ អ្នកអាចស្នើសុំវេជ្ជបណ្ឌិតស្រីបាន។

បន្ទាប់មក វេជ្ជបណ្ឌិតនឹងប្រើគ្រឿងប្រដាប់ពេទ្យម៉្យាងហៅថា ស្ពេឃ្យូឡុម ឬប្រដាប់សំរាប់វែក (Speculum) ដើម្បីបើកយោនី។ គេប្រើកូនច្រាស ឬបន្ទះឈើ ឬជ័រតូចមួយដើម្បីកៀរយ៉ាងស្រាលៗយកកោសិកាខ្លះពីកស្បូន។

គេដាក់កោសិកាទាំងនេះនៅពីលើកូនបន្ទះកញ្ចក់មួយ ហើយផ្ញើទៅមន្ទីរពិសោធន៍ ដែលនៅទីនោះគេពិនិត្យមើលកោសិកាទាំងនោះតាមអតិសុខុមទស្សន៍ (Microscope)។



## ចំណែកលទ្ធផលនោះវិញយ៉ាងណាដែរ?

នៅពេលអ្នកធ្វើតែសផាប់ស្មៀ នេះគឺជាការសំខាន់ដែលអ្នកត្រូវសួរវេជ្ជបណ្ឌិតថាតើពេលណា និងធ្វើយ៉ាងណាដើម្បីឲ្យអ្នកបានដឹងអំពីលទ្ធផល។

**លទ្ធផលភាគច្រើន មានភាពធម្មតា។**

## ចុះប្រសិនបើលទ្ធផលមានភាពមិនប្រក្រតីវិញ តើត្រូវធ្វើយ៉ាងណាដែរ?

ប្រសិនបើលទ្ធផលនោះមិនមានភាពធម្មតា នេះមិនមែនបានសេចក្ដីថាអ្នកកើតជម្ងឺមហារីកទេ។

វាប្រហែលជាមានន័យថា អ្នកមានអាការៈរោគសាមញ្ញដែលវេជ្ជបណ្ឌិតអាចព្យាបាលបាន។

គឺជាការសំខាន់ដែលអ្នកត្រូវពិភាក្សាជាមួយវេជ្ជបណ្ឌិតអំពីលទ្ធផលនោះ ព្រមទាំងអំពីវិធីព្យាបាលដែលអ្នកត្រូវទទួល។

## តើបន្ទាប់មកទៀតត្រូវធ្វើយ៉ាងណា?

ជួនកាល ស្ត្រីប្រហែលជាត្រូវការធ្វើតែសផាប់ស្មៀឲ្យបានញឹកញាប់។ ស្ត្រីខ្លះទៀតប្រហែលជាត្រូវទៅជួបវេជ្ជបណ្ឌិតឯកទេស។ ប្រសិនបើមានកោសិកាមិនប្រក្រតី គេនឹងព្យាបាលកោសិកានោះ។

អ្នកត្រូវនិយាយឲ្យបានច្បាស់ ជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីការព្យាបាលដែលល្អវិសេសសំរាប់អ្នក។

## ខ្ញុំដល់ពេលអស់រដូវ (Menopause) ហើយ តើខ្ញុំនៅតែត្រូវធ្វើតែសផាប់ស្មៀឬ?

អ្នកត្រូវធ្វើតែស ពីព្រោះគ្រោះថ្នាក់កើតមហារីកកស្បូនមានកាន់តែខ្លាំង នៅពេលអ្នកមានអាយុកាន់តែច្រើន។ ហេតុដូច្នេះ នេះគឺជាការសំខាន់ដែលអ្នកត្រូវធ្វើតែសផាប់ស្មៀរៀងរាល់២ឆ្នាំម្ដង ទោះបីជាអ្នកអស់រដូវក៏ដោយ។

## ខ្ញុំបានកាត់ស្បូនចេញ (Hysterectomy) រួចហើយ តើខ្ញុំនៅតែត្រូវធ្វើតែសផាប់ស្មៀឬ?

អ្នកប្រហែលជានៅតែត្រូវធ្វើតែសផាប់ស្មៀដដែល។ សូមនិយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នក។"

## ខ្ញុំសំគាល់ឃើញមានធ្លាក់ឈាមមិនប្រក្រតីខ្លះៗ

ប្រសិនបើអ្នកមានធ្លាក់ឈាមមិនធម្មតា ឬមានធ្លាក់រំអិលសៗ (Discharge) ពីយោនី សូមទៅជួបវេជ្ជបណ្ឌិតរបស់អ្នកជាបន្ទាន់។

## តើការធ្វើតែសផាប់ស្មៀអស់ថ្លៃប៉ុន្មាន?

វេជ្ជបណ្ឌិត មន្ទីរព្យាបាល និងមជ្ឈមណ្ឌលសុខភាពខ្លះធ្វើផាប់ស្មៀជូនអ្នកដោយពុំគិតថ្លៃឡើយ។ កន្លែងខ្លះទៀតតម្រូវឲ្យអ្នកបង់ថ្លៃ។ សូមអ្នកសួរតម្លៃជាមុនសិន មុននឹងអ្នកធ្វើការណាត់ពេលជួបមួយ។ សូមជ្រើសរើសយកទីកន្លែងណាមួយដែលងាយស្រួលទៅមក ហើយដែលអ្នកមានលទ្ធភាពអាចបង់ថ្លៃបាន។

## ខ្ញុំមិនចាំពេលណាដែលខ្ញុំធ្វើតែសផាប់ស្មៀចុងក្រោយ

វេជ្ជបណ្ឌិតដែលព្យាបាលអ្នក ប្រហែលជាមានប្រព័ន្ធសំរាប់រំឭកប្រាប់អ្នកពីពេលវេលាដែលអ្នកត្រូវធ្វើតែសផាប់ស្មៀលើកក្រោយ។

នៅតាមរដ្ឋ ឬដែនដីនីមួយៗ គេមានរបៀបកត់ចូលបញ្ជីនូវលទ្ធផលនៃតែសផាប់ស្មៀរបស់អ្នក។ ភាពសម្ងាត់នៃពត៌មានទាំងនេះត្រូវបានច្បាប់ការពារ។

អ្នកកាន់បញ្ជី គឺជាអ្នកជួយរំឭកប្រសិនបើពេលធ្វើតែសផាប់ស្មៀ ឬការព្យាបាលបន្តរបស់អ្នកហួសថ្ងៃកំណត់។

ប្រសិនបើអ្នកមិនចង់ឲ្យគេកត់ពត៌មានចូលក្នុងបញ្ជីទេ សូមនិយាយប្រាប់វេជ្ជបណ្ឌិតរបស់អ្នក។

## តើខ្ញុំត្រូវទៅកន្លែងណា ដើម្បីធ្វើតែសផាប់ស្មៀ?

ស្ត្រីខ្លះមានការខ្មាស់អៀនអំពីការធ្វើតែសផាប់ស្មៀនេះ។ វាប្រហែលជាជួយឲ្យអ្នកមិនខ្មាស់អៀន ប្រសិនបើអ្នកជ្រើសរើសមនុស្ស និងទីកន្លែងដែលធ្វើឲ្យអ្នកស្រួលចិត្តនឹងទៅជួបគេ។ អ្នកអាចធ្វើការណាត់ពេលជួបមួយជាមួយវេជ្ជបណ្ឌិតរបស់អ្នក គិលានុប្បដ្ឋាកយិកា ឬមន្ទីរគំរោងគ្រួសារ (Family Planning Clinic) នៅក្នុងដំបន់ដែលអ្នករស់នៅ។ អ្នកអាចស្នើសុំវេជ្ជបណ្ឌិតស្រីម្នាក់ ដើម្បីឲ្យគេធ្វើតែសផាប់ស្មៀជូនអ្នក។

ប្រសិនបើអ្នកចង់បានអ្នកបកប្រែភាសាឲ្យជួយអ្នកនៅពេលនោះ សូមប្រាប់គេឲ្យដឹងនៅពេលធ្វើការណាត់ជួប។

**ចំពោះពត៌មានបន្ថែមទៀត** ស្ដីអំពីកិច្ចការពារជម្ងឺមហារីកកស្បូន សូមទូរស័ព្ទលេខ **13 15 56** (ដោយបង់តម្លៃទូរស័ព្ទដូចក្នុងដំបន់)។

ប្រសិនបើអ្នកមានបញ្ហាពិបាកក្នុងការទាក់ទងជាភាសាអង់គ្លេស សូមទូរស័ព្ទទៅកិច្ចបំរើបកប្រែភាសាអត្ថបទ និងភាសានិយាយ (Translation and Interpreting Service) លេខ **13 14 50** ដើម្បីសុំជំនួយ។ អ្នកត្រូវបង់តម្លៃទូរស័ព្ទ ដូចថ្លៃទូរស័ព្ទក្នុងដំបន់។

**www.cervicalscreen.health.gov.au**

AUSTRALIA

A joint Australian Government &
State/Territory Health initiative